ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation Religion King

លេខៈ ៣៤៧ ឧ.វ.ប.ន-អ.វ.ប.ន.ពិឌស

# សេចក្តីសម្រេច
# ស្តីពី
# ការបង្កើតអង្គភាពបរិវត្តកម្មឌីជីថល
# នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២១/៥៦៤ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិសេដ្ឋកិច្ចនិងសង្គមឌីជីថល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.បន ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

## សម្រេច

**ប្រការ១.-**

បង្កើតអង្គភាពបរិវត្តកម្មឌីជីថលនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សរសេរអក្សរកាត់ថា **អ.ប.ឌ.** ដែលមានសមាសភាពដូចខាងក្រោមៈ



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទៈ (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

| | | | | |
|---|---|---|---|---|
| ១. ឯកឧត្តម | ទ្រី | សុផល | អគ្គនាយកនៃអគ្គនាយកដ្ឋាន វ.ប.ន. | ប្រធាន |
| ២. លោកជំទាវ | ពេជ | សូរិយា | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | អនុប្រធាន |
| ៣. លោកស្រី | ផាន | សោភា | អគ្គនាយករងនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ | អនុប្រធាន |
| ៤. លោកស្រី | សេង | មូលិកា | ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. នៃអគ្គនាយកដ្ឋាន វ.ប.ន. | អនុប្រធានប្រចាំការ |
| ៥. លោក | ចិន | សុវណ្ណ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. នៃអគ្គនាយកដ្ឋាន វ.ប.ន. | សមាជិក |
| ៦. លោក | ទេព | សុវណ្ណ | អនុប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. អគ្គនាយកដ្ឋាន វ.ប.ន. | សមាជិក |
| ៧. លោក | បុត្រ | សុភ័ក្ត្រ | អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល វ.ប.ន. នៃវិទ្យាស្ថានជាតិ វ.ប.ន. | សមាជិក |
| ៨. លោក | ចិន្តា | ម៉ានិត | ប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ៩. លោក | ថន | សុចិត្រា | អនុប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១០. លោក | ស៊ាម | វិរៈ | អនុប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១១. លោក | អ៊ិប | ស៊ីមីអូរិកសេម | អនុប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១២. លោក | នង | សីហា | អនុប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១៣. លោក | ហ៊ឹម | ទិវ័ន្ត | អនុប្រធានការិយាល័យព័ត៌មាន និងកិច្ចការទូទៅ នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១៤. លោក | ទេព | សុភានុមា | អនុប្រធានការិយាល័យព័ត៌មាន និងកិច្ចការទូទៅ នៃនាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន. | សមាជិក |
| ១៥. លោក | ប្រាក់ | ច័ន្ទវីរៈសត្យា | មន្ត្រីឧទ្ទកាល័យ | សមាជិក |
| ១៦. កញ្ញា | មាស | សុជីនិត្យ | មន្ត្រីរាជការ | សមាជិក |
| ១៧. កញ្ញា | ញឹមខេមរា | រូហ្សា | ជំនួយការឯកឧត្តមរដ្ឋលេខាធិការប្រចាំការ | សមាជិក។ |

**ប្រការ២.-**

អង្គភាពនេះ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- គ្រប់គ្រងការងារបរិវត្តកម្មឌីជីថល
- សហការជាមួយអគ្គនាយកដ្ឋានពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់អំពីដំណើរការនិងលំហូរនៃកិច្ចការដែលត្រូវធ្វើបរិវត្តកម្មឌីជីថល
- កំណត់លក្ខណៈពិសេស និងមុខងារផ្សេងៗរបស់ប្រព័ន្ធដែលត្រូវអភិវឌ្ឍ
- រៀបចំរបាយការណ៍ជូន ក្រុមការងារដឹកនាំ និងជំរុញឌីជីថលូបនីយកម្មនៃក្រសួង ឧ.វ.ប.ន.
- បំពេញភារកិច្ចផ្សេងទៀតដែល គ.ជ.ឌ. និងរដ្ឋមន្ត្រី ប្រគល់ជូន។

**ប្រការ៣.-**

អង្គភាពនេះ អាចប្រើប្រាស់មន្ត្រីនៅតាមអគ្គនាយកដ្ឋានសាមី ដើម្បីជួយដល់ដំណើរការការងារពាក់ព័ន្ធនឹងបរិវត្តកម្មឌីជីថលរបស់ក្រសួង ឧ.វ.ប.ន. តាមការចាំបាច់។

**ប្រការ៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល ប្រធានមន្ទីរ ឧ.វ.ប.ន. រាជធានី-ខេត្ត គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ២០២៣

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យរដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ